# KUMAMOTO ភាពទាក់ទាញនៃការធ្វើការ

## 1
### អាកាសធាតុកក់ក្តៅ និងងាយស្រួលក្នុងការរស់នៅ



សីតុណ្ហភាពប្រចាំឆ្នាំជាមធ្យមនៅក្នុងខេត្តគូម៉ាម៉ូតូគឺប្រហែលជា 17 ℃ ដែលធ្វើឱ្យវាមានអាកាសធាតុក្តៅ និងមានផាសុខភាព។ ម្យ៉ាងវិញទៀត អ្នកក៏អាចនឹងទទួលបានអារម្មណ៍នៅរដូវកាលទាំងបួនដែលជាលក្ខណៈធម្មតារបស់ប្រទេសជប៉ុន ដូចជាផ្កាសាគូរ៉ានៅនិទាឃរដូវ ស្លឹកពណ៌នៅរដូវស្លឹកឈើជ្រុះ និងព្រិលក្នុងរដូវរងា។

## 2
### ធម្មជាតិសម្បូរបែប និងទឹកស្អាត



គូម៉ាម៉ូតូជាទីក្រុងដែលសម្បូរទៅដោយទឹកជាច្រើនដូច្នេះហើយបានជាគេហៅថា "ទីក្រុងនៃទឹក"។ ទឹកនោះផងដែរត្រូវបានចិញ្ចឹមបីបាច់ដោយធម្មជាតិដ៏សម្បូរបែប រួមទាំងភ្នំ អាសូ និងជួយជីវិតមនុស្សឲ្យមានភាពជាសម្បូរបែប។

## 3
### នៅជិតអាស៊ី



Kumamoto គឺជាខេត្តនៅជិតអាស៊ីក្នុងប្រទេសជប៉ុន ហើយអ្នកក៏អាចត្រលប់ទៅផ្ទះវិញក្នុងរយៈពេលមួយថ្ងៃតាមយន្តហោះ។ លើសពីនេះ មានមធ្យោបាយធ្វើដំណើរផ្សេងដូចជា Shinkansen ក៏មានផងដែរ ដែលវាធ្វើឱ្យមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ទីក្រុងធំៗដូចជា Tokyo និង Fukuoka។

## ＼ លូហ្វីជាមួយនិងមិត្តភក្តិគាំទ្រ Kumamoto! ／

© Eiichiro Oda / Shueisha

ខេត្ត Kumamoto គឺជាស្រុកកំណើតរបស់ Eiichiro Oda ដែលជាអ្នកបង្កើតរឿងតុក្កតា "ONE PIECE"!

"គម្រោងការសាងសង់ឡើងវិញ ONE PIECE Kumamoto" កំពុងដំណើរការហើយ!



## កុំបារម្ភអ្នកអាចធ្វើការប្រឹក្សាជាភាសាខ្មែរបានប្រសិនជាបើអ្នកមានបញ្ហាអ្វី!

មានមជ្ឈមណ្ឌលជំនួយនៅខេត្តគូម៉ាម៉ូតូ ដែលអ្នកអាចពិគ្រោះជាភាសាខ្មែរបាន។

ខ្លឹមសារនៃការប្រឹក្សា៖ ការប្រឹក្សាស្តីអំពីរបៀបរស់នៅ (នីតិវិធីនៃការស្នាក់នៅ ស្តីពីកង្វល់ការងារ ការថែទាំសុខភាព សុខុមាលភាព ការសម្រាលកូន ការចិញ្ចឹមកូន ការអប់រំកុមារ។ល។)




### មជ្ឈមណ្ឌលគាំទ្រជនបរទេសនៃខេត្ត Kumamoto

ជាន់ទី 8, អគារមេការិយាល័យប្រចាំខេត្ត,
6-18-1 Suizenji, Chuo-ku, Kumamoto City

**Tel:080-4275-4489**

ម៉ោងពិគ្រោះ៖ ច័ន្ទ ដល់ សុក្រ ពីម៉ោង ៨:៣០ ព្រឹក ដល់ ៥:០០ ល្ងាច។
បិទ៖ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃឈប់សម្រាក ថ្ងៃទី ២៩ ខែធ្នូ ដល់ថ្ងៃទី ៣ ខែមករា



### ទីប្រឹក្សាទូទៅផ្លាហ្សាសម្រាប់ជនបរទេសរបស់ទីក្រុង Kumamoto

ជាន់ទី2, សាលផ្លាស់ប្តូរអន្តរជាតិទីក្រុងគូម៉ាម៉ូតូ,
4-18 Hanabatake-cho, Chuo-ku, Kumamoto City

**Tel:096-359-4995**

ម៉ោងពិគ្រោះ៖ 10:00 ព្រឹក ដល់ 6:00 ល្ងាច
បិទ៖ ថ្ងៃទី 2 និងទី 4 (ប្រសិនបើថ្ងៃច័ន្ទជាថ្ងៃឈប់សម្រាក ថ្ងៃអង្គារបន្ទាប់)

គូម៉ាម៉ូតូ ក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងការងារ ផ្នែកគោលនយោបាយពាណិជ្ជកម្ម និងឧស្សាហកម្ម។

# Let's work in Japan Kumamoto

## តោះធ្វើការនៅ គូម៉ាម៉ូតូ(Kumamoto)!

**-កំណែកម្ពុជា-**












© Eiichiro Oda / Shueisha




## មានប្រជាជនកម្ពុជាជាច្រើន

កំពុងបច្ចុប្បន្នសកម្មនៅគូម៉ាម៉ូតូមិនមែនត្រឹមតែការងារប៉ុណ្ណោះទេ.អ្នកក៏អាចរស់នៅដោយមានថ្ងៃឈប់សម្រាកយ៉ាងពេញលេញផងដែរ។តើអ្នកចង់សាកល្បងធ្វើការនៅគូម៉ាម៉ូតូទេ?

វីដេអូផ្សព្វផ្សាយកំពុងផ្សាយ!

**INTERVIEW**

## ការងារផងថ្ងៃឈប់សម្រាកផងគឺពេញលេញ

កសិកម្ម | អុំ សម្បត្តិ





វាពិតជាល្អខ្លាំងណាស់ដែលអាចស្ទូចត្រីនៅសមុទ្រក្បែរទីនេះ!

បច្ចុប្បន្នខ្ញុំកំពុងធ្វើការនៅចម្ការប៉េងប៉ោះ។ ប៉េងប៉ោះនៅគូម៉ាម៉ូតូពេញនិយមដោយសារតែមានរសជាតិផ្អែម និងឆ្ងាញ់។ បរិមាណផលិតកម្មនោះគឺមានភាពខ្ពស់បំផុតនៅក្នុងប្រទេសជប៉ុន។ យើងកំពុងរៀនពីរបៀបដាំប៉េងប៉ោះ និងបន្លែ ដោយយកដើម កាត់ស្លឹក និងកាត់ពន្លកថ្មី ខណៈពេលពិនិត្យមើល ដើម្បីប្រាកដថាគ្មានជំងឺ។អ្នកគ្រប់គ្នានៅក្នុងខេត្តគូម៉ាម៉ូតូគឺមានចិត្តល្អ ហើយទាំងនៅកន្លែងធ្វើការចៅហ្វាយរបស់ខ្ញុំ និងមនុស្សចាស់នៅទីនេះពួកគាត់រាប់អានខ្ញុំដោយចិត្តសប្បុរស។ ថ្ងៃឈប់សម្រាករបស់ខ្ញុំ ខ្ញុំចូលចិត្តនេសាទនៅឆ្នេរសមុទ្រ! គូម៉ាម៉ូតូគឺជាកន្លែងដែលមានបរិយាកាសដ៏ល្អបំផុតដែលអាចអោយយើងរីករាយទាំងការងារ និងថ្ងៃឈប់សម្រាក!



## ខ្ញុំបានចេញទៅជួបមិត្តភក្ត័



ឧស្សាហកម្មផលិតកម្ម | សុខ មករា







ខ្ញុំដើរទិញទំនិញជាមួយមិត្តភក្តិគឺជារឿងដែរសប្បាយរីករាយ។

ខ្ញុំបាទធ្វើការនៅក្រុមហ៊ុនផលិតគ្រឿងយន្តម៉ាស៊ីន។ ខ្ញុំមានអារម្មណ៍ល្អដូចទទួលបានបរិយាកាសដែលខ្ញុំអាចធ្វើការងារផ្សេងៗ។ ខេត្តគូម៉ាម៉ូតូជាខេត្តមួយដែលមានប្រជាជនកម្ពុជារស់នៅច្រើនជាងគេនៅប្រទេសជប៉ុន ហើយមានប្រជាជនកម្ពុជាជាច្រើនធ្វើការនៅកន្លែងធ្វើការរបស់ខ្ញុំ។ខ្ញុំបានបង្កើតមិត្តភ័ក្តិដែលមិនអាចជំនួសបាន ហើយនៅថ្ងៃឈប់សម្រាក ពួកយើងទៅទិញឥវ៉ាន់ជាមួយគ្នា ហើយពួកយើងក៏កំពុងរស់នៅក្នុងជីវិតដ៏រីករាយ។

WORKING IN KUMAMOTO IS ENJOYABLE!

# WORKING IN KUMAMOTO IS ENJOYABLE!

WORKING IN KUMAMOTO IS ENJOYABLE!

## មានសុវត្ថិភាព និងផាសុខភាព ក្នុងការរស់នៅ



កសិកម្ម | ប៊ុន ស្រីនី (ឆ្វេង) គេន ឈរី (ស្តាំ)



ខ្ញុំស្រលាញ់ គូម៉ាម៉ូតូដែលមានសុវត្ថិភាព និងមានសន្តិសុខល្អ។

ការងាររបស់ពួកយើងដែរកំពុងតែធ្វើគឺការតម្រៀបបន្លែ ប្រមូលផលផ្លែឈើ ការបែងចែក និងការវេចខ្ចប់ដាក់ក្នុងប្រអប់។ អ្នករាល់គ្នានៅកន្លែងធ្វើការគឺចិត្តល្អ ហើយទោះបីជាអ្នកមិនយល់ពីការងារក៏ដោយ ក៏គេបង្រៀនយើងយ៉ាងសប្បុរស។ ខ្ញុំបានរកឃើញអ្នកដែលដូចជាម្តាយខ្ញុំ។គូម៉ាម៉ូតូមានសន្តិសុខល្អ ហើយនិងសុវត្ថិភាពខ្លាំងណាស់។ ម្យ៉ាងវិញទៀត តម្លៃទំនិញទាប ហើយការរស់នៅក៏មានភាពងាយស្រួលផងដែរ។ តើអ្នកចង់មកធ្វើការជាមួយគ្នានៅគូម៉ាម៉ូតូទេ?



DAY OFF

## សូមរីករាយជាមួយថ្ងៃឈប់សម្រាក!





Amakusa



Mt. Aso



Kumamoto City Center



Kumamoto Castle



©2010 kumamoto pref. kumamon